**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរទន្លេសាប**

គណៈកម្មាធិការលទ្ធកម្ម

លេខ : ..១៥១.......អទស.សជណ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃការទារផ្គត់ផ្គង់សម្ភារៈបច្ចេកទេស ព័ត៌មានវិទ្យាឆ្នាំ ២០១៩

អាជ្ញាធរទន្លេសាប (ក្រសួងធនធានទឹក និងឧតុនិយម) សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ៖ អាជ្ញាធរទន្លេសាប នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់សម្ភារៈបច្ចេកទេសព័ត៌មានវិទ្យា ឆ្នាំ ២០១៩ របស់អាជ្ញាធរទន្លេសាប ។

អាជ្ញាធរទន្លេសាប បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មអាជ្ញាធរទន្លេសាប (ក្រសួងធនធានទឹក និងឧតុនិយម) ដែលមានអាសយដ្ឋានអគារលេខ ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទង ០៩៥ ៩៩០ ៩០១, ០៨០ ៥៥៥៥ ៨០) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ៩:០០នាទីព្រឹក ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៩ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង៩:០០ នាទីព្រឹក ថ្ងៃទី **១៨ ខែកញ្ញា ឆ្នាំ ២០១៩** ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ ចន្ទ ៤ រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៩

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**លឹម គានហោ**

ចម្លងជូន ៖

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ